# របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
# ក្រោមប្រធានបទ បុគ្គលណាប្រាថ្នាសេចក្តីសុខដើម្បីខ្លួន ទៅបៀតបៀនអ្នកដទៃ បុគ្គលនោះនឹងជាប់ជំពាក់ពៀរ ។

**Website: www.hoksavann.org**

ថ្ងៃទី២៣ មេសា ២០១០



គាថាមួយបទនៅក្នុងធម្មបទនៃគម្ពីរពុទ្ធសាសនាពោលថា បុគ្គលណាប្រាថ្នាសេចក្តីសុខដើម្បីខ្លួន ដោយការធ្វើសេចក្តីទុក្ខឲ្យកើតមានដល់បុគ្គលដទៃ បុគ្គលនោះតែងជាប់ជំពាក់ដោយគ្រឿងជំពាក់គឺពៀរ និងមិនរួចផុតអំពីពៀរវេរានេះ ចេញមកពីបាលីថា បរទុក្ខូបធានេន យោអត្តនោ សុខមិច្ឆតិ វេរសំសគ្គសំសដ្ឋោ វេរា សោ ន បរិមុច្ចតិ ។ អត្ថន័យនៃគាថានេះ គឺមនុស្សគ្រប់រូបតែងតែប្រាថ្នាសេចក្តីសុខដើម្បីខ្លួន ចង់ឲ្យខ្លួនរស់នៅបានចំរើនរុងរឿង បែរជាមានមនុស្សខ្លះប្រព្រឹត្តផ្ទុយអំពីហេតុដែលនាំឲ្យបានសេចក្តីសុខ គឺប្រព្រឹត្តធ្វើអំពើអាក្រក់ប៉ះពាល់ដល់សេចក្តីសុខរបស់អ្នកដទៃទៅវិញ ។ ព្រះពុទ្ធសំដែងថា មនុស្សកើតមកត្រូវបំពេញការងារត្រឹមត្រូវ ការងារពុំមានទោស ការងារដែលធ្វើឲ្យអ្នកដទៃមានទុក្ខព្រួយភ័យខ្លាច ។ ខាងចុងនៃគាថានេះបញ្ជាក់ថា បើបុគ្គលប្រព្រឹត្តធ្វើឲ្យគេមានទុក្ខ បុគ្គលនោះតែងទទួលនូវអំពើបាប តាមកម្រិតអកុសលដែលខ្លួនបានប្រព្រឹត្ត ជាពិសេសមានអំពើអាក្រក់ខ្លះ មានការចង់ពៀរជាមួយអ្នកដទៃផង ។

អំពើដែលធ្វើឲ្យគេមានទុក្ខមានច្រើនយ៉ាង មានបុគ្គលខ្លះក្នុងសង្គមមនុស្សនេះ ទៅលួចប្លន់ទ្រព្យសម្បត្តិអ្នកដទៃ រហូតសម្លាប់ម្ចាស់ទ្រព្យថែមទៀត ។ ធ្វើឲ្យគេមានទុក្ខ គឺធ្វើឲ្យគេអស់ទ្រព្យសម្បត្តិ ថែមទាំងជីវិតគេត្រូវស្លាប់ទៀត ។ ការលួចប្រពន្ធ កូន និងប្តីរបស់អ្នកដទៃ គឺអ្នកដទៃគេចង់ជួបជុំប្តីប្រពន្ធកូនចៅមិនចង់បែកបាក់គ្នាដូចខ្លួនដែរ ។ បើអ្នកកាន់អំណាចមិនអនុវត្តឲ្យបានត្រឹមត្រូវតាមមុខងារនាទីរបស់ខ្លួន តាមរបបប្រជាធិបតេយ្យទេ និងធ្វើឲ្យប្រជាពលរដ្ឋមានទុក្ខ ដោយប្រជាពលរដ្ឋគ្មានសិទ្ធិសេរីភាពពេញបរិបូណ៌ ដែលជាមូលដ្ឋាននៃសេចក្តីសុខសន្តិភាពនិងការលូតលាស់ខាងសេដ្ឋកិច្ចគ្រួសារនិងសេដ្ឋកិច្ចជាតិ ។ បើអ្នកដឹកនាំរដ្ឋបង្កើតសង្គ្រាម និងធ្វើឲ្យប្រជាពលរដ្ឋមានទុក្ខលំបាក ដោយការស្លាប់និងព្រាត់ប្រាស់គ្នាពិការបាក់ដៃបាក់ជើងជាដើម ។

អ្នកសាងបាបកម្ម ដោយការលួចប្លន់ទ្រព្យសម្បត្តិអ្នកដទៃឬរបស់ជាតិ បើគេចាប់បាននឹងទទួលទោសទណ្ឌកម្មក្នុងបច្ចុប្បន្ន បើគេចាប់ពុំបានទេ គឺគេចពុំផុតអំពីទោសទៅមុខទៀតដែរ ។ នៅក្នុងគម្ពីរពុទ្ធសាសនានិយាយថា អ្នកដែលលួចទ្រព្យសម្បត្តិរបស់អ្នកដទៃនិងរបស់ជាតិ នឹងធ្លាក់ទៅសោយទុក្ខក្នុងនរក លុះសេសសល់ផលកម្ម បើបានកើតមកជាមនុស្សវិញ បើមានទ្រព្យសម្បត្តិក៏ទុកពុំគង់ ចេះតែវិនាសទៅវិញដោយហេតុផ្សេងៗ ។ ចំពោះអ្នកដែលសម្លាប់គេដោយខ្លួនឯងក្តី ប្រើគេឲ្យសម្លាប់ក្តី នឹងធ្លាក់ទៅសោយទុក្ខក្នុងនរក លុះសេសសល់ផលកម្ម បើបានកើតមកជាមនុស្សឬជាសត្វ មានអាយុខ្លីត្រូវគេសម្លាប់វិញជាច្រើនជាតិ ។

បើអ្នកដឹកនាំរដ្ឋដើរផ្លូវខុស និងធ្វើឲ្យប្រជាពលរដ្ឋទាំងប្រទេសមានទុក្ខព្រោះអ្នកដឹកនាំរដ្ឋ ប្រៀបដូចជាអ្នកកាច់ចង្កូតរថយន្តឬនាវា បើកាច់ចង្កូតគ្មានការប្រុងប្រយ័ត្ន នឹងទទួលគ្រោះថ្នាក់ដល់អ្នកជិះ ។ បើអ្នកកាន់អំណាចមិនបានដឹកនាំប្រជាពលរដ្ឋឲ្យបានសុខសន្តិភាព និងមានជីវភាពលូតលាស់ទេ អ្នកកាន់អំណាចនោះនឹងអស់ការគាំទ្រពីប្រជាពលរដ្ឋ ហើយបើមានកំហុសធ្វើបាបប្រជាពលរដ្ឋ នឹងធ្លាក់ទៅសោយទុក្ខក្នុងនរកដូចប្រជាពលរដ្ឋទូទៅដែរ ។

ផ្ទុយពីអត្ថន័យខាងលើនេះ បុគ្គលបើចង់បានសេចក្តីសុខដើម្បីខ្លួន មិនត្រូវបៀតបៀនអ្នកដទៃដោយមធ្យោបាយអាក្រក់ណាមួយឡើយ ព្រោះនាំឲ្យចងពៀរនឹងគ្នាផង នាំឲ្យមានទោសទុក្ខទៅមុខផង ។ ផ្ទុយទៅវិញ ព្រះពុទ្ធសំដែងថា បុគ្គលប្រាថ្នាសេចក្តីសុខដើម្បីខ្លួន ត្រូវផ្តល់សេចក្តីសុខឲ្យដល់អ្នកដទៃផងតាមលទ្ធភាពរបស់ខ្លួន ។ ត្រូវប្រើមេត្តាករុណាអាណិតអាសូរដល់អ្នកដទៃ ឲ្យដូចជាអាណិតអាសូរខ្លួនឯង ។ នេះជាហេតុនាំឲ្យបានសុខ ដោយមិនមានពៀរវេរាជាមួយអ្នកដទៃ ។ ចំពោះអ្នកកាន់អំណាចវិញ ដើម្បីកុំឲ្យមានកម្មពៀរវេរាជាមួយប្រជាពលរដ្ឋ ត្រូវតែអនុវត្តកិច្ចការឲ្យបានល្អត្រឹមត្រូវប្រកបដោយយុ-ត្តិធម៌ កុំបៀតបៀនប្រជាពលរដ្ឋដោយមធ្យោបាយណាមួយ ផ្ទុយទៅវិញ ត្រូវបំរើប្រជាពលរដ្ឋដោយចិត្តបរិសុទ្ធ ដោយគោ-រពជីវិតរបស់ប្រជាពលរដ្ឋឲ្យដូចជាជីវិតរបស់ខ្លួន ។ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ គប្បីប្រជាពលរដ្ឋនិងអ្នកកាន់អំណាចខ្មែរ ដែលគោរពព្រះពុទ្ធសាសនាយកទៅពិចារណា ដើម្បីខ្មែរគ្រប់ឋានៈរស់នៅជាមួយគ្នាបានសុខសាន្តនៅក្នុងប្រទេសកម្ពុជាមាតុភូមិ ។៚

*　　　*

*